គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលបឋម និងមិនផ្លូវការនៃការបោះឆ្នោតជាតិឆ្នាំ២០១៣

ខុមហ្វ្រែលសូមប្រកាសជូននូវលទ្ធផលបឋម និងមិនផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ ដែលបានធ្វើឡើងកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣នេះ។ លទ្ធផលនេះ គឺប្រមូលចេញមកពីការិយាល័យរាប់សន្លឹកឆ្នោត ដោយអ្នកសង្កេតការណ៍ខុមហ្វ្រែលពី១,៤៧០ការិយាល័យរាប់សន្លឹកឆ្នោតដែលបានកំណត់ចេញពីអ្នកបានចុះឈ្មោះបោះឆ្នោតសំណាកសរុប ចំនួន ៦៨៧,០៧៩នាក់ ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោតសរុបចំនួន ៩,៦៧៥,៤៥៣នាក់ ក្នុងកំរិតជឿជាក់ (Confident Level) ៩៩% និងកំរិតលំអៀង (Margin of Error) 0.១៥% និងកំរិតលំអៀងសំរាប់ការិយាល័យ ២,៦២%(កំរិតលំអៀងសំរាប់ការិយាល័យក្នុងខេត្តនីមួយៗមាន៥%)។

| លេខរៀង | ឈ្មោះខេត្ត | គណបក្សប្រជាជនកម្ពុជា | | គណបក្សសង្គ្រោះជាតិ | |
|---|---|---|---|---|---|
| | | ចំនួនអាសនៈ | ភាគរយ | ចំនួនអាសនៈ | ភាគរយ |
| ១ | បន្ទាយមានជ័យ | 4 | 56.79% | 2 | 27.84% |
| ២ | បាត់ដំបង | 5 | 52.97% | 3 | 39.02% |
| ៣ | កំពង់ចាម | 8 | 41.71% | 10 | 44.44% |
| ៤ | កំពង់ឆ្នាំង | 2 | 49.21% | 2 | 41.18% |
| ៥ | កំពង់ស្ពឺ | 3 | 45.15% | 3 | 48.22% |
| ៦ | កំពង់ធំ | 3 | 48.52% | 3 | 36.81% |
| ៧ | កំពត | 3 | 50.27% | 3 | 40.28% |
| ៨ | កណ្តាល | 5 | 44.69% | 6 | 51.66% |
| ៩ | កោះកុង | 1 | 68.15% | 0 | 25.57% |
| ១០ | ក្រចេះ* | 1 | 46.88% | 2 | 46.96% |
| ១១ | មណ្ឌលគិរី | 1 | 66.60% | 0 | 21.93% |

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

| | | | | | |
|---|---|---|---|---|---|
| ១២ | ភ្នំពេញ | 5 | 39.50% | 7 | 57.73% |
| ១៣ | ព្រះវិហារ | 1 | 63.64% | 0 | 26.50% |
| ១៤ | ព្រៃវែង | 5 | 46.21% | 6 | 48.01% |
| ១៥ | ពោធិ៍សាត់ | 3 | 72.89% | 1 | 22.81% |
| ១៦ | រតនគិរី | 1 | 76.49% | 0 | 14.980% |
| ១៧ | សៀមរាប | 4 | 50.37% | 2 | 36.49% |
| ១៨ | ព្រះសីហនុ | 1 | 59.35% | 0 | 34.53% |
| ១៩ | ស្ទឹងត្រែង | 1 | 75.03% | 0 | 16.05% |
| ២០ | ស្វាយរៀង | 3 | 60.06% | 2 | 33.97% |
| ២១ | តាកែវ | 4 | 45.92% | 4 | 45.34% |
| ២២ | ឧត្តរមានជ័យ | 1 | 56.03% | 0 | 27.93% |
| ២៣ | កែប | 1 | 75.55% | 0 | 17.69% |
| ២៤ | ប៉ៃលិន | 1 | 57.80% | 0 | 36.85% |
| សរុប | | 67 | 49.49% | 56 | 43.05% |

** លទ្ធផលខេត្តក្រចេះស្ថិតនៅក្នុងការផ្ទៀងផ្ទាត់ដោយទិន្នន័យមិនទាន់គ្រប់គ្រាន់*


***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖***

១. កញ្ញា **គង់ រ៉ាវីន** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ៖ ០១២ ៦៥៤ ៩៥០

២. លោក **កន សាវាង្ស** មន្ត្រីគ្រប់គ្រងទិន្នន័យជាន់ខ្ពស់ ទូរស័ព្ទ៖ ០១១ ៨៨៤ ៨៤០


**<u>បេសកកម្ម</u>** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។